Inter-Parliamentary Union
For democracy. For everyone.

# កម្ពុជា

CMBD/២៧ - ចាន់ ចេង

CMBD/៤៨ - (អ្នកស្រី) មួរ សុខហួរ

CMBD/៤៩ - កែវ ភីរម្យ

CMBD/៥០ - ហូ វ៉ាន់

CMBD/៥១ - ឡុង រី

CMBD/៥២ - នុត រំដួល

CMBD/៥៣ - ម៉ែន សុថាវរិន

CMBD/៥៤ - រៀល ខេមរិន្ទ

CMBD/៥៥ - ហុង សុខហួរ

CMBD/៥៦ - គង់ សភា

CMBD/៥៧ - ញ៉ែយ ចំរើន

CMBD/៥៨ - សម រង្ស៊ី

CMBD/៥៩ - អ៊ុំ សំអាន

CMBD/៦០- គឹម សុខា

CMBD/៦១ - (អ្នកស្រី) ថាក់ ឡានី

## *សេចក្តីសម្រេចអនុម័តជាឯកច្ឆ័នដោយក្រុមប្រឹក្សាភិបាលនៃសហភាពអន្តរសភា នាសម័យប្រជុំលើកទី១៩៩ (ទីក្រុងហ្សឺណែវ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦)* [1]

ក្រុមប្រឹក្សាអភិបាលនៃសហភាពអន្តរសភា (IPU)

*យោង*សំណុំរឿងក្តីរបស់តំណាងរាស្ត្រចំនួន១២ រូប ដូចមានរាយឈ្មោះខាងក្រោម មកពីគណៈបក្សសង្គ្រោះជាតិ (CNRP) រួមមាន៖ (១) លោក ចាន់ ចេង (២) អ្នកស្រី មួរ សុខហួរ លោក កែវ ភីរម្យ

[1] គណៈប្រតិភូកម្ពុជាបានសំដែងខរក្សាទុករបស់ខ្លួនចំពោះសេចក្តីសម្រេចនេះ។

លោក ហូ វ៉ាន់ លោក ឡុង រី លោក នុត រំដួល លោក ម៉ែន សុថាវិរិន និងលោក រៀល ខេមរិន្ទ (៣) លោក ហុង សុខហួរ (៤) លោក គង់ សភា និង លោក ញ៉យ ចំរើន និង (៥) លោក សម រង្ស៊ី មេដឹកនាំគណៈបក្សប្រឆាំង និងសេចក្ដីសម្រេចដែលបានអនុម័តនាសម័យប្រជុំលើកទី១៩៨ របស់ខ្លួន (នៅទីក្រុងលូសាកា ខែមីនា ឆ្នាំ២០១៦)។

*មានផងដែរនៅចំពោះមុខក្រុមប្រឹក្សាភិបាលនេះនូវ*សំណុំរឿងក្ដីលោក អ៊ុំ សំអាន លោក គឹម សុខា អ្នកស្រី ថាក់ ឡានី តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាកម្ពុជា មកពីគណៈបក្សសង្គ្រោះជាតិ (CNRP) ដែលត្រូវបានពិនិត្យដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់សភា ស្របតាមនីតិវិធីស្ដីពីការពិនិត្យ និងចំណាត់ការបណ្ដឹង (ឧបសម្ព័ន្ធ១ នៃវិធាន និងការអនុវត្តដែលបានពិនិត្យឡើងវិញ)។

*ដោយយោង*របាយការណ៍ចុងក្រោយ(CL/199/11(b)-R.1) ស្ដីពីដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការនេះ មកកាន់ប្រទេសកម្ពុជា ក្នុងខែកុម្ភៈ ឆ្នាំ២០១៦។

*ដោយបានពិនិត្យពិចារណានូវ*លិខិតចុះថ្ងៃទី១១ ខែកក្កដា និងលិខិតចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ របស់អគ្គលេខាធិការរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងព័ត៌មានដែលបានបញ្ជូនដោយអ្នកប្ដឹង និងតតីយភាគីដែលអាចជឿទុកចិត្តបាន។

*យោង*ជំនួបកិច្ចប្រជុំដែលបានធ្វើឡើងជាមួយគណៈប្រតិភូកម្ពុជា ដែលចូលរួមក្នុងសម័យប្រជុំសភាIPU លើកទី១៣៥ និងលោក សម រង្ស៊ី (ទីក្រុងហ្ស៊ឺណែវ ខែតុលា ឆ្នាំ២០១៦)។

*ដោយរំលឹកឡើងវិញ* នូវព័ត៌មានដែលមានរួចហើយនៅក្នុងសំណុំឯកសារ ទាក់ទងនឹងសំណុំរឿងក្ដីរបស់សមាជិកសភាគណៈបក្សប្រឆាំងចំនួន ១២ រូប ខាងក្រោមនេះ៖

- លោក ចាន់ ចេង ជាសមាជិកមួយរូបនៃរដ្ឋសភា ត្រូវបានតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ បន្ទាប់ពីដំណើរការក្ដីនៅទ្រឹងមួយរយៈពេលវែងកន្លងមក ហើយដែលគេជឿជាក់ថាត្រូវបានលើកលែងចោទប្រកាន់នៅឆ្នាំ២០១២ ប៉ុន្តែភ្លាមៗក៏ស្រាប់តែរឿងក្ដីនេះដំណើរការឡើងវិញនៅពាក់កណ្ដាលឆ្នាំ២០១៤ នៅខណៈពេលដែលមានការជាប់គាំងនយោបាយតានតឹង រវាងគណៈបក្សកាន់អំណាច និងគណៈបក្សប្រឆាំង។ លោក ចាន់ ចេង បានប្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចរបស់សាលាដំបូង ហើយកំពុងរង់ចាំសវនាការនៅសាលាឧទ្ធរណ៍។ អភ័យឯកសិទ្ធិរបស់គាត់ មិនទាន់ត្រូវបានដកហូតនៅឡើយទេ។ លោកនៅមានសេរីភាព។

- អ្នកស្រី មូរ សុខហួរ លោក កែវ ភីរម្យ លោក ហូ វ៉ាន់ លោក ឡុង រី លោក នុត រំដួល លោក ម៉ែន សុថាវិរិន និងលោក រៀល ខេមរិន្ទ ទាំងអស់គ្នាគឺជាសមាជិកសភា ត្រូវបានចាប់ខ្លួននៅថ្ងៃ

ទី១៥ ខែកក្កដា ឆ្នាំ២០១៤ ជាមួយនឹងសកម្មជនគណៈបក្សប្រឆាំងផ្សេងទៀត បន្ទាប់ពីមានបាតុកម្មមួយដែលអំពាវនាវឲ្យបើកឡើងវិញនូវទីលានតវ៉ាមួយកន្លែងនៅរាជធានីភ្នំពេញ ដែលគេស្គាល់ថាជាទីលានសេរីភាព (ឬទីលានប្រជាធិបតេយ្យ) បានកើតមានអំពើហឹង្សា។ ពួកគេត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់ពីបទដឹកនាំកុប្បកម្ម បទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងញុះញង់ឲ្យប្រព្រឹត្តបទល្មើស ហើយដែលត្រូវប្រឈមទោសជាប់ពន្ធនាគាររហូតដល់ទៅ ៣០ ឆ្នាំ។ គណៈកម្មាធិការ បានទទួលភស្តុតាងជាខ្សែវីដេអូយ៉ាងច្បាស់ថា សមាជិកសភាបានព្យាយាមទប់ស្កាត់ និងបញ្ឈប់អំពើហិង្សា (បើទោះជាអ្នកតវ៉ាមិនស្តាប់ពួកគេក៏ដោយ) ទន្ទឹមនេះ មិនមានភស្តុតាងណាមួយបានបញ្ជូនមក ដើម្បីបញ្ជាក់ការអះអាងពីការចូលរួមរបស់ពួកគេដោយផ្ទាល់ ក្នុងអំពើហិង្សានេះឡើយ ឬថាអំពើហិង្សានេះបំពេញលក្ខខណ្ឌតម្រូវដោយច្បាប់នេះ ពីបទល្មើសកុប្បកម្មនោះក៏ទេដែរ។ អភ័យឯកសិទ្ធិសភារបស់ពួកគេ មិនទាន់ត្រូវបានដកហូតនៅឡើយទេ។ សាមីសមាជិកសភាទាំងនេះ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ននៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ បន្ទាប់ពីមានការប្រកាសអំពីកិច្ចព្រមព្រៀងនយោបាយមួយ រវាងរដ្ឋាភិបាល និងគណៈបក្សប្រឆាំង ដើម្បីបញ្ចប់វិបត្តិនយោបាយ។ ទោះជាដូច្នេះក្តី បទចោទប្រកាន់ប្រឆាំងពួកគេ នៅមិនទាន់ទម្លាក់ចោលនៅឡើយទេ។ ការស៊ើបអង្កេតជាសម្ងាត់របស់តុលាការនៅតែបន្ត ហើយមិនទាន់មានការកំណត់កាលបរិច្ឆេទសម្រាប់ការជំនុំជម្រះនៅឡើយ។ ពួកគេមានសេរីភាព។

- លោក ហុង សុខហួរ ជាសមាជិកព្រឹទ្ធសភា ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ បន្ទាប់ពីមានខ្សែវីដេអូឃ្លីបមួយ ត្រូវបានបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់មេដឹកនាំគណៈបក្សប្រឆាំងគឺលោក សម រង្ស៊ី នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥។ ខ្សែវីដេអូឃ្លីបនេះ បានបង្ហាញរូបភាពរបស់លោក ហុង សុខហួរ កំពុងពិភាក្សាលើទស្សនៈរបស់គាត់ អំពីបញ្ហាព្រំដែនវៀតណាម-កម្ពុជា ដែលជាបញ្ហាមួយដ៏ចម្រូងចម្រាស់ និងរសើបនៅកម្ពុជា និងបង្ហាញច្បាប់ចម្លងនៃអត្ថបទសន្ធិសញ្ញាព្រំដែនវៀតណាម-កម្ពុជាឆ្នាំ១៩៧៩ ដែលនិយាយថា ព្រំដែននឹងត្រូវបានរំលាយ និងធ្វើការកំណត់ជាថ្មី ដែលបានបង្ហាញពីភាពមិនត្រឹមត្រូវ។ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចោទប្រកាន់សមាជិកព្រឹទ្ធសភារូបនេះពីបទក្បត់ជាតិ និងបានចេញបញ្ជាឲ្យចាប់ខ្លួនគាត់។ ក្រោយមក សមាជិកព្រឹទ្ធសភារូបនេះ ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ និងត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារសាធារណៈក្លែងក្លាយ និងញុះញង់ឲ្យមានចលាចលក្នុងសង្គម។ គាត់អាចទទួលរងទោសជាប់ពន្ធនាគាររហូតដល់ទៅ១៧ ឆ្នាំ។ អភ័យឯកសិទ្ធិរបស់គាត់ មិនត្រូវបានដកហូតទេ ដោយសារអាជ្ញាធរបានចាត់ទុកថា គាត់ត្រូវបានចាប់ខ្លួនក្នុងការប្រព្រឹត្តបទល្មើសជាក់ស្តែង។ គាត់ស្ថិតនៅក្នុងការឃុំខ្លួននៅឡើយ ដោយសារការស្នើសុំនៅក្រៅឃុំរបស់គាត់ ត្រូវបានបដិសេធជាលក្ខណៈប្រព័ន្ធដោយតុលាការ។ ការជំនុំជម្រះលើសំណុំ

រឿងរបស់គាត់ បានផ្ដើមធ្វើនៅខែតុលា ឆ្នាំ២០១៥ ដែលចាប់ពីពេលនោះមក ត្រូវបានលើកពេលជាច្រើនលើកច្រើនសារ។

- លោក គង់ សភា និង លោក ញ៉យ ចំរើន ជាសមាជិកសភា ត្រូវបានគេទាញទម្លាក់ពីរថយន្តរបស់ពួកគេ ហើយត្រូវគេវាយដំដោយហឹង្សា ខណៈពេលដែលពួកគេកំពុងធ្វើដំណើរចេញពីវិមានរដ្ឋសភានៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។ នៅពេលនោះ បាតុកម្មមួយប្រឆាំងនឹងគណៈបក្សប្រឆាំង ត្រូវបានរៀបចំឡើងដោយគណៈបក្សកាន់អំណាច កំពុងធ្វើនៅខាងមុខវិមានរដ្ឋសភា។ ទាំងមន្ត្រីសន្តិសុខរដ្ឋសភា ទាំងមន្ត្រីនគរបាលមានវត្តមាននៅទីនោះ មិនបានចាត់វិធានការណាមួយទាំងមុនពេល ក្នុងពេល ឬបន្ទាប់ពីការវាយប្រហារនោះ ដូចដែលបានបង្ហាញតាមរយៈខ្សែវីដេអូក្លីបនៅកន្លែងកើតហេតុនេះស្រាប់។ ការវាយប្រហារនេះ បានធ្វើឲ្យសមាជិកសភាទាំងពីររូបនេះ រងរបួសធ្ងន់ធ្ងរ។ ការវាយប្រហារនេះ ត្រូវបានរដ្ឋសភាធ្វើការថ្កោលទោស និងបានផ្ដួចផ្ដើមការស៊ើបអង្កេតដែលឈានទៅចាប់ខ្លួនជនសង្ស័យចំនួនបីរូប នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ បន្ទាប់ពីពួកគេបានចេញមកសារភាពថាបានចូលរួមនៅក្នុងអំពើហិង្សានេះ។ មិនមានវិធានការបន្ថែមណាមួយ ត្រូវបានចាត់ទៅលើអ្នកវាយប្រហារ ឬអ្នកផ្ដើមគំនិតផ្សេងទៀតទេ ទោះបីជាសាមីសមាជិកសភាទាំងនោះ បានដាក់ពាក្យបណ្ដឹងរួចហើយក្ដី ហើយខ្សែវីដេអូយ៉ាងច្បាស់ក្រឡែតអំពីសកម្មភាពវាយប្រហារនេះ បានបង្ហាញឲ្យឃើញពីអត្តសញ្ញាណរបស់អ្នកវាយប្រហារ និងសកម្មភាព ដែលពួកគេកំពុងនិយាយទាក់ទងគ្នាជាមួយអ្នកដទៃទៀតតាមរយៈវិទ្យុទាក់ទងក្ដី។

- លោក សម រង្ស៊ី មេដឹកនាំគណៈបក្សប្រឆាំង និងជាសមាជិកសភាមួយរូប ត្រូវបានក្លាយជាគោលដៅ ដោយករណីបណ្ដឹងនៅតុលាការកាន់តែច្រើនឡើងៗ ដែលចោទប្រកាន់លើរូបគាត់គិតចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៥ (រាប់ទាំងសំណុំរឿងក្ដីមួយ ដែលទាក់ទងនឹងសំណុំរឿងក្ដីរបស់សមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ ដែលបង្ហោះវីដេអូឃ្លីបលើទំព័រហ្វេសប៊ុករបស់គាត់)។ អភ័យឯកសិទ្ធិរបស់គាត់ មិនត្រូវបានដកហូតទេ ប៉ុន្តែអាណត្តិសភារបស់គាត់ ត្រូវបានដកហូត ពាក់ព័ន្ធនឹងសំណុំរឿងក្ដីរបស់គាត់នៅសាលាដំបូង។ គាត់បានបង្ខំចិត្តធ្វើនិរទេសខ្លួនទៅក្រៅប្រទេស ដើម្បីគៀចវេសពីការទទួលទោសជាប់ពន្ធនាគារ ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៥។

*ដោយរំលឹកបន្ថែមឡើងវិញ*នូវព័ត៌មានខាងក្រោម ទាក់ទងនឹងសំណុំរឿងទាំងនេះ មុនពេលមានចំណាត់ការៈ

- ដោយឈរលើមូលដ្ឋានករណីអញ្ញត្រកម្ម គណៈកម្មាធិការតាំងពីដំបូងមក បានសម្រេចរក្សាករណីទាំងនេះទុកជាការសម្ងាត់ ដើម្បីទុកឱកាសឲ្យគណៈបក្សទាំងពីរ ស្វែងរកដំណោះស្រាយ

តាមរយៈការសន្ទនានយោបាយ ដោយសារកិច្ចសន្ទនានេះបានបន្តធ្វើឡើងរវាងគណៈបក្សកាន់អំណាច គឺគណៈបក្សប្រជាជនកម្ពុជា(CPP) និងគណៈបក្សសង្គ្រោះជាតិ(CNRP) បន្ទាប់ពីមានកិច្ចព្រមព្រៀងមួយក្នុងខែកក្កដា ឆ្នាំ២០១៤។ កិច្ចព្រមព្រៀងនេះ បានបញ្ចប់វិបត្តិក្រោយការបោះឆ្នោតឆ្នាំ២០១៣ និងបានបង្កើតយន្តការមួយសម្រាប់កិច្ចសន្ទនារវាងគណៈបក្សនយោបាយធំៗទាំងពីរ ដែលមានតំណាងនៅក្នុងរដ្ឋសភា ដែលគេស្គាល់ថាជា "វប្បធម៌សន្ទនា"។ វប្បធម៌សន្ទនានេះ ត្រូវបានភាគីទាំងពីរចាត់ទុកថាមានសារៈសំខាន់ ដើម្បីបញ្ចប់វប្បធម៌ហឹង្សាទូទៅកន្លងមក។ វប្បធម៌នេះ បានបើកចំហបន្ថែមទៀត សម្រាប់ការសន្ទនានយោបាយនៅក្នុងស្ថាប័នសភា និងបានអនុញ្ញាតឲ្យភាគីទាំងអស់សម្រេចបាននូវវឌ្ឍនភាពលើបញ្ហាមួយចំនួនដែលជាផលប្រយោជន៍ជាតិ នៅចន្លោះពីខែកក្កដា ឆ្នាំ២០១៤ និងនៅពាក់កណ្តាលឆ្នាំ២០១៥។

- គណៈប្រតិភូកម្ពុជានាសម័យប្រជុំសភាIPU លើកទី១៣៣ (ទីក្រុងហ្សឺណែវ ខែតុលា ឆ្នាំ២០១៥) បានស្វាគមន៍សំណើរបស់គណៈកម្មាធិការនេះ ដើម្បីធ្វើទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា។ ទស្សនកិច្ចនេះ បានធ្វើចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយសមាជិកសភាIPU គឺលោក អាលី អេ អារ៉ាឌី (Mr. Ali A. Alaradi) និងលោក អាលីអូនេ អាបាតាលីប ហ្គេយេ (Mr. Alioune Abatalib Gueye)។ ដំណើរទស្សនកិច្ចនេះ មានគោលដៅសំខាន់ចំនួនពីរៈ ទីមួយដើម្បីឲ្យគណៈកម្មាធិការនេះយល់ដឹងច្រើនបន្ថែមទៀត អំពីសំណុំរឿងក្តីរបស់សាមីតំណាងរាស្ត្រចំនួន ១២ រូបរបស់គណៈបក្សប្រឆាំង និងអំពីបរិបទសិទ្ធិមនុស្ស និងនយោបាយ ដែលបានកើតឡើង; ទីពីរដើម្បីជួយជម្រុញឲ្យមានដំណោះស្រាយ ដែលគួរជាទីគាប់ចិត្តក្នុងសំណុំរឿងក្តីទាំងនេះផ្ទាល់ ស្របតាមក្របខណ្ឌរដ្ឋធម្មនុញ្ញរបស់កម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ គណៈកម្មាធិការចាត់ទុកដំណើរទស្សនកិច្ចរបស់ខ្លួនថាជា "ដំណើរទស្សនកិច្ចជាជម្រើសចុងក្រោយ" បន្ទាប់ពីគណៈកម្មាធិការបានផ្តល់ពេលវេលាយ៉ាងច្រើនម្តងហើយម្តងទៀត ឲ្យភាគីទាំងពីរស្វែងរកដំណោះស្រាយតាមរយៈការចរចារ។

*ដោយពិនិត្យឃើញ* ថាក្រុមប្រឹក្សាភិបាលទទួលយកសេចក្តីសង្កេតបឋម និងអនុសាសន៍របស់គណៈកម្មាធិការអំពីដំណើរទស្សនកិច្ច នៅសម័យប្រជុំលើកទី១៣៤ របស់សភា IPU (លូសាកា ខែមីនា ឆ្នាំ២០១៦) ដែលឥឡូវនេះត្រូវបានបញ្ជាក់យ៉ាងពេញលេញ។ របាយការណ៍ចុងក្រោយនៃដំណើរទស្សនកិច្ចនេះ បានរួមបញ្ចូលបន្ថែមទៀតនូវសេចក្តីសន្និដ្ឋានជាក់លាក់ លើសំណុំរឿងក្តីបុគ្គលនីមួយៗនៅចំពោះមុខក្រុមប្រឹក្សាភិបាល ហើយបានរកឃើញថាមានតំណាងរាស្ត្រចំនួន១២ រូបជាជនរងគ្រោះដោយការរំលោភសិទ្ធិជាមូលដ្ឋានរបស់ពួកគេ។ ក្រុមប្រឹក្សានេះ បានធ្វើអនុសាសន៍ជាក់លាក់ ដើម្បីដោះស្រាយស្ថានភាពរបស់ពួកគេ ដោយអនុលោមតាមក្របខ័ណ្ឌច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ។

*ដោយពិនិត្យឃើញ*ថា សេចក្តីសង្កេតជាផ្លូវការរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លើរបាយការណ៍នៃដំណើរទស្សនកិច្ចនេះ ដែលបានចែករំលែកក្នុងលិខិតចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ បានបញ្ជាក់បន្ថែមទៀតពីជំហរនានា ដែលបានបង្ហាញកន្លងមកដោយអាជ្ញាធរ នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនេះ និងត្រូវបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធយ៉ាងត្រឹមត្រូវ ទៅក្នុងរបាយការណ៍ចុងក្រោយ។ *ដោយពិនិត្យឃើញ*ថា អាជ្ញាធរធ្វើការបដិសេធ ដែលថាការរំលោភណាមួយលើសិទ្ធិមនុស្ស ត្រូវបានប្រព្រឹត្តក្នុងករណីស្ថិតក្នុងដៃ និងបន្តអះអាងថាសាមីតំណាងរាស្ត្រគណៈបក្សប្រឆាំងជាជនល្មើស ដែលត្រូវផ្តន្ទាទោសតាមច្បាប់។ *និងថា* នេះគឺជាកិច្ចការរបស់តុលាការសុទ្ធសាធ ទុកឲ្យតុលាការជាអ្នកសម្រេច ហើយថានេះមិនមែនជារឿងនយោបាយ ដែលអាចដោះស្រាយតាមរយៈវប្បធម៌សន្ទនាបានឡើយ ព្រោះថាកិច្ចសន្ទនានយោបាយមិនអាចជំនួស ឬបំពានច្បាប់បានឡើយ នេះបើតាមទស្សនៈរបស់ពួកគេ។

*ដោយពិនិត្យឃើញ*ថា បន្ទាប់ពីដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការនេះ ភាគីទាំងពីរបានបង្ហាញពីបំណងប្រាថ្នារបស់ខ្លួន ក្នុងការបន្តកិច្ចសន្ទនានយោបាយ ប៉ុន្តែថាវានៅតែជាប់គាំងរហូតមកទល់ពេលនេះ។ គ្មានការរីកចម្រើនណាមួយត្រូវបានធ្វើឡើង លើសំណុំរឿងក្តីដែលកំពុងស្ថិតក្នុងការពិនិត្យនេះទេ។ ស្ថានភាពនេះបានធ្លាក់ចុះកាន់តែខ្លាំងថែមទៀត នេះបើយោងតាមព័ត៌មានដូចខាងក្រោម និងតាមការចោទប្រកាន់ទាំងឡាយ ដែលបានដាក់ជូនពិនិត្យដោយអ្នកប្តឹង និងភាគីទីបីដែលអាចជឿទុកចិត្តបាន ដែលករណីសំណុំរឿងក្តីទាំងនេះ នៅមិនទាន់ទទួលបាននូវសេចក្តីសង្កេតរបស់អាជ្ញាធរនៅឡើយទេ។

- **ការធ្លាក់ចុះនៃស្ថានភាពរបស់លោក សម រង្ស៊ី៖**

- នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ លោក សម រង្ស៊ី ត្រូវបានគេរកឃើញថា មានពិរុទ្ធភាពពីបទបរិហាកេរ្តិ៍ប្រធានរដ្ឋសភា នេះបើយោងតាមអ្នកប្តឹង។ សវនាការត្រូវបានធ្វើឡើងដោយកំបាំងមុខជនជាប់ចោទ និងមេធាវីរបស់គាត់។ សាលក្រមនេះ ត្រូវបានប្រកាសតែប្រមាណជា ១០នាទីប៉ុណ្ណោះ បន្ទាប់ពីចៅក្រមជំនុំជម្រះដកខ្លួនទៅពិចារណា។ សេចក្តីសម្រេចរបស់តុលាការ មិនបាននិយាយយោងដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ឬអភ័យឯកសិទ្ធិសភានោះទេ។ លោក សម រង្ស៊ី បានប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះ។

- បណ្តឹងព្រហ្មទណ្ឌថ្មីកើតមានជាហូរហែរផងដែរប្រឆាំងនឹងលោក សម រង្ស៊ី នេះបើយោងតាមអ្នកប្តឹងដែលរួមមាន៖ (១) ការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ថ្មី ដែលបានធ្វើឡើងនៅដើមខែសីហា ឆ្នាំ២០១៦ ដោយលោកនាយករដ្ឋមន្ត្រីទាក់ទងនឹងសេចក្តីថ្លែងការណ៍ ដែលបានធ្វើឡើងដោយលោក សម រង្ស៊ី ដែលចោទប្រកាន់លោកនាយករដ្ឋមន្ត្រីថាបានចូលរួមពាក់ព័ន្ធនឹងការធ្វើឃាតលោក កែម ឡី អ្នកវិភាគនយោបាយ (២) ដីកាចាប់ខ្លួនថ្មីមួយដែលបានចេញ

ប្រឆាំងនឹងលោក សម រង្ស៊ី នៅចុងខែសីហា ឆ្នាំ២០១៦ ដែលចោទប្រកាន់គាត់ពីបទសមគំនិតក្នុងការក្លែងបន្លំឯកសារ ការប្រើប្រាស់ឯកសារសាធារណៈក្លែងក្លាយ និងបទញុះញង់ក្នុងករណីចម្រូងចម្រាសមួយផ្សេងទៀត ទាក់ទងនឹងព្រំដែនកម្ពុជា-វៀតណាម (៣) បណ្តឹងបរិហារកេរ្តិ៍មួយផ្សេងទៀត ដែលបានប្តឹងដោយអ្នកគ្រប់គ្រងវេបសាយរបស់គណៈបក្សប្រជាជនកម្ពុជា បន្ទាប់ពីលោក សម រង្ស៊ី បានអះអាងថា គណៈបក្សប្រជាជនបានបង្កើតគណនេយ្យហ្វេសប៊ុកក្លែងក្លាយ ដើម្បីចុច "Like" Page របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើដូច្នេះដើម្បីទទួលបានចំនួន "Likes" ច្រើនជាងលោក សម រង្ស៊ី (៤) បណ្តឹងថ្មីមួយត្រូវបានគេប្តឹងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃទាក់ទងនឹងការអំពាវនាវឲ្យមានការតវ៉ាទ្រង់ទ្រាយធំ ដែលធ្វើឡើងដោយលោក សម រង្ស៊ី ក្នុងខែកញ្ញា។

- អ្នកប្តឹងអះអាងថា នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ លោកនាយករដ្ឋមន្ត្រីបានចេញសេចក្តីណែនាំដល់អាជ្ញាធរពាក់ព័ន្ធទាំងអស់ ឲ្យ "ប្រើគ្រប់វិធី និងមធ្យោបាយ" ដើម្បីរារាំងលោក សម រង្ស៊ី មិនឲ្យចូលក្នុងប្រទេសកម្ពុជាបន្ទាប់ពីគាត់ (សម រង្ស៊ី) បានប្រកាសប្រាប់ពីបំណងរបស់គាត់ចង់វិលត្រឡប់ពីការនិរទេសខ្លួននៅក្រៅប្រទេស ចូលរួមក្នុងការបោះឆ្នោតនាពេលខាងមុខ។

- **ការស៊ើបអង្កេតលើករណីវាយប្រហារក្នុងខែតុលា ឆ្នាំ២០១៥ លើលោក គង់ សភា និង លោក ញ៉យ ចំរើន**

- ភាគីទីបីដែលគួរឲ្យជឿទុកចិត្តបានបានបង្ហាញថា ជនសង្ស័យទាំងបីនាក់ ត្រូវបានចាប់ខ្លួនបន្ទាប់ពីចេញមកសារភាពថាបានប្រព្រឹត្តអំពើល្មើសនោះ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលបួនឆ្នាំ (រាប់ទាំងរយៈពេលព្យួរទោសបីឆ្នាំផងដែរ) នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦។ ទាំងអ្នកប្តឹង និងទាំងអាជ្ញាធរ មិនបានចែករំលែកព័ត៌មានបច្ចុប្បន្នភាព អំពីស្ថានការណ៍វិវឌ្ឍន៍ជាដុំកំភួនក្នុងករណីនេះទេ។

- អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ គឺអង្គការឃ្លាំមើលសិទ្ធិមនុស្ស(HRW) បានថ្លែងនៅក្នុងរបាយការណ៍មួយចេញផ្សាយនៅចុងខែឧសភា ឆ្នាំ២០១៦ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់ក្នុងឧប្បត្តិហេតុនោះថា ជនសង្ស័យបានសារភាពថាពួកគេជាសមាជិកនៃអង្គភាពអង្គរក្សរបស់លោកនាយករដ្ឋមន្ត្រី ប៉ុន្តែបានអះអាងថា ពួកគេមិនបានធ្វើតាមបញ្ជាថ្នាក់លើទេ គឺធ្វើតាមតែកំហឹងផ្ទាល់ខ្លួនបុគ្គលតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ អង្គការឃ្លាំមើលសិទ្ធិមនុស្ស(HRW) បានធ្វើការសន្និដ្ឋានថា សវនាការនេះត្រូវបានរៀបចំឡើង ដើម្បីបិទបាំងការទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើល្មើសនេះ ជាជាងលាតត្រដាងវាដោយផ្អែកលើមូលហេតុថា (១) ការវាយប្រហារនេះមានសញ្ញាកត់សំគាល់ទាំងអស់នៃប្រតិបត្តិការ ដែលបានធ្វើ

ឡើងដោយកងកំលាំងសន្តិសុខរបស់រដ្ឋកម្ពុជា (២) ចម្លើយសារភាពរបស់ជនសង្ស័យ បានធ្វើឡើងនៅក្នុងកាលៈទេសៈគួរឲ្យសង្ស័យ ហើយមិនស៊ីសង្វាក់គ្នានឹងភស្តុតាង ដែលបង្ហាញតាមរយៈវីដេអូជាក់ស្តែង (៣) ជនសង្ស័យបានបដិសេធមិនឆ្លើយសំណួរ អំពីខ្សែសង្វាក់បញ្ជានៅក្នុងអំឡុងពេលសវនាការសាធារណៈ (៤) ចៅក្រមរារាំងការព្យាយាមរបស់មេធាវីរបស់សមាជិកសភាពីររូប មិនឲ្យសាកសួរជនសង្ស័យអំពីតួនាទីរបស់ថ្នាក់លើរបស់ពួកគេ ហើយថាតើពួកគេបានទទួលបញ្ជាឲ្យចូលរួមក្នុងការវាយប្រហារនេះឬយ៉ាងណា។ ចៅក្រម និងព្រះរាជអាជ្ញាបានលើកអំណះអំណាងថា ការតាំងសំណួរបែបនេះជាបន្តបន្ទាប់ គឺស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ ហើយភស្តុតាងបង្ហាញពីការចូលរួមដោយផ្ទាល់របស់អ្នកដទៃទៀតជាច្រើននៅក្នុងការវាយប្រហារនេះ មិនត្រូវបានអើពើនៅក្នុងអំឡុងពេលសវនាការ (៥) ការស៊ើបអង្កេតរកអ្នកផ្តើមគំនិត អ្នករៀបចំផែនការ និងអ្នកចូលរួមដទៃទៀត នៅក្នុងការវាយប្រហារប្រឆាំងនឹងសមាជិកសភានេះ ត្រូវបានរាំងខ្ទប់ទោះបីមានភស្តុតាងច្បាស់លាស់ហើយក៏ដោយ។

- សេចក្តីសម្រេចរបស់សភាអឺរ៉ុបចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ បានអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សុំធានាឲ្យមានការស៊ើបអង្កេតពេញលេញ និងមិនលំអៀង លើករណីវាយប្រហារនោះដោយមានការចូលរួមពីអង្គការសហប្រជាជាតិ។

- **ករណីថ្មីមួយចំនួន ដែលបានបញ្ជូនទៅគណៈកម្មាធិការសិទ្ធិមនុស្សរបស់សភា**

- យោងតាមអ្នកប្តឹង សមាជិកសភាទាំងបីរូបដូចខាងក្រោម នៃគណៈបក្សសង្គ្រោះជាតិ ក៏ជាគោលដៅផងដែរ នៃការចោទប្រកាន់ផ្អែកលើហេតុផលនយោបាយ ការរំលោភអភ័យឯកសិទ្ធិសភា និងសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពួកគេក្នុងការបញ្ចេញមតិ និងក្នុងការបង្កើតសមាគម ការមិនរើសអើង និងសិទ្ធិទទួលបាននូវបទដ្ឋាននៃនីតិវិធីត្រឹមត្រូវ។

- **លោក អ៊ុំ សំអាន** ជាសមាជិកសភាមកពីគណៈបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ នៅពេលដែលគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ ហើយត្រូវបានផ្តន្ទាទោសនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំកន្លះ ពីបទញុះញង់ឲ្យមានអំពើហិង្សា និងការរើសអើង។ យោងតាមអ្នកប្តឹង សំណុំរឿងក្តីនេះកើតមានឡើងបន្ទាប់ពីគាត់បានបង្ហោះមតិយោបល់ និងខ្សែវីដេអូនៅលើហ្វេសប៊ុកក្នុងឆ្នាំ២០១៥ អំពីបញ្ហាព្រំដែនកម្ពុជា-វៀតណាម ក្នុងការអះអាងជាពិសេសថា រដ្ឋាភិបាលបានប្រើប្រាស់ "ផែនទីក្លែងក្លាយ" ដើម្បីកំណត់ព្រំដែន។ អភ័យឯកសិទ្ធិសភារបស់គាត់ មិនត្រូវបានដកទេ។ យោងតាមអ្នកប្តឹង អាជ្ញាធរបានអះអាងថា គាត់ត្រូវបានចាប់ខ្លួនក្នុងបទល្មើសជាក់ស្តែង ដោយសារតែបទល្មើសនេះនៅតែបន្ត ដរាបណាដែលមតិយោបល់របស់គាត់មិនត្រូវបានដកចេញពីហ្វេសប៊ុកទេនោះ (ទោះជាយ៉ាងណាក៏ដោយ តុលាការបានបដិសេធពាក្យសុំធានាឲ្យនៅក្រៅឃុំ ដោយឈរ

លើហេតុផលថា មានហានិភ័យដែលគាត់អាចនឹងបំផ្លាញភស្តុតាង ដោយដកមតិយោបល់របស់គាត់ចេញពីហ្វេសប៊ុក ប្រសិនជាដោះលែងឲ្យគាត់នៅក្រៅឃុំបណ្ដោះអាសន្ននោះ)

- **លោក កឹម សុខា** ជាអនុប្រធានគណៈបក្សសង្គ្រោះជាតិ និងជាប្រធានស្ដីទីនៃគណៈបក្សនេះចាប់តាំងពីលោក សម រង្ស៊ី បាននិរទេសខ្លួនម្ដងទៀត ក្នុងខែតុលា ឆ្នាំ២០១៥។ គាត់ជាអនុប្រធានទីមួយនៃរដ្ឋសភាកម្ពុជា រហូតដល់ខែតុលា ឆ្នាំ២០១៥ និងនៅតែជាសមាជិកមួយរូបរបស់រដ្ឋសភារហូតមកទល់ពេលនេះ។ យោងតាមអ្នកប្ដឹង លោក កឹម សុខា ត្រូវបានគេអះអាងថាជាជនរងគ្រោះពីការយាយីខាងក្រោមនេះ តាំងពីខែមេសា ឆ្នាំ២០១៥៖ ការគំរាមកំហែងម្ដងហើយម្ដងទៀត (ជាពិសេសចាប់ពីខែមេសា ដល់ខែតុលា ឆ្នាំ២០១៥) ការវាយប្រហារលើលំនៅដ្ឋានរបស់គាត់ (ខែតុលា ឆ្នាំ២០១៥) គាត់ត្រូវគេដកចេញពីមុខតំណែងជាអនុប្រធានទីមួយនៃរដ្ឋសភា (ខែតុលា ឆ្នាំ២០១៥) និងករណី "ស្រីមុំ" ដែលបាននិងកំពុងបន្តចាប់តាំងពីចុងខែកុម្ភៈ ឆ្នាំ២០១៦។ ក្នុងករណីនេះ មានការអះអាងថា លោក កឹម សុខា មានទំនាក់ទំនងស្នេហាជាមួយជាងកាត់សក់របស់គាត់ ហើយបានផ្ដល់អំណោយដ៏មានតម្លៃឲ្យនាង។ ទោះបីជាអភ័យឯកសិទ្ធិរបស់គាត់មិនត្រូវបានដកក្ដី ក៏ការប៉ុនប៉ងចាប់ខ្លួនលោក កឹម សុខា ត្រូវបានធ្វើឡើងនៅក្នុងខែឧសភា ឆ្នាំ២០១៦ ហើយគាត់បានស្នាក់នៅក្នុងទីស្នាក់ការកណ្ដាលរបស់គណៈបក្សសង្គ្រោះជាតិ ចាប់តាំងពីពេលនោះមក ក្រោមការឃុំខ្លួនក្នុងផ្ទះតាមព្រឹត្តន័យ នេះបើយោងតាមអ្នកប្ដឹង។ លោក កឹម សុខា ក៏ត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំមួយខែផងដែរ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ ចំពោះការបដិសេធមិនចូលខ្លួន ដើម្បីសាកសួរ។

- **អ្នកស្រី ថាក់ ឡានី** ជាសមាជិកព្រឹទ្ធសភានៃគណៈបក្សសង្គ្រោះជាតិ ត្រូវបានចោទប្រកាន់ដោយលោកនាយករដ្ឋមន្ត្រីពីបទបង្កាច់បង្ខូច និងការញុះញង់ នៅដើមខែសីហា ឆ្នាំ២០១៦ បន្ទាប់ពីមានខ្សែវីដេអូមួយត្រូវបានគេបង្ហោះតាមអនឡាញ ដែលក្នុងនោះទំនងជាចង់និយាយថាលោកនាយករដ្ឋមន្ត្រីបានចូលរួមពាក់ព័ន្ធក្នុងករណីឃាតកម្មលើលោក កែម ឡី អ្នកវិភាគន យោបាយ។ យោងទៅតាមអ្នកប្ដឹង សមាជិកព្រឹទ្ធសភារូបនេះ បានបដិសេធថាគាត់មិនបានធ្វើសេចក្ដីថ្លែងការណ៍នេះទេ ហើយអះអាងថា ខ្សែវីដេអូនេះ ត្រូវបានគេកែសម្រួល។ សមាជិកព្រឹទ្ធសភារូបនេះ ត្រូវបានតុលាការកោះហៅពីរដងឲ្យបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញាមុនពេលអភ័យឯកសិទ្ធិសភារបស់អ្នកស្រីត្រូវបានដកនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦។ បច្ចុប្បន្ន អ្នកស្រី ឡានី កំពុងស្ថិតក្នុងការនិរទេសខ្លួន។ សវនាការរបស់អ្នកស្រី បានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦។

*ដោយយល់ឃើញ*ថា អាជ្ញាធរកម្ពុជាមិនទាន់បានផ្ដល់ព័ត៌មានជាផ្លូវការ ឬសេចក្ដីសង្កេតរបស់ពួកគេលើសំណុំរឿងក្ដី និងការចោទប្រកាន់ថ្មី មកគណៈកម្មាធិការ។

*ដោយយល់ឃើញ*បន្ថែមទៀតថា អ្នកប្តឹងបានអះអាងថា សំណុំរឿងក្តីរបស់សមាជិកសភាទាំង ១៥ រូបនៃគណៈបក្សសង្គ្រោះជាតិដែលស្ថិតក្រោមការពិនិត្យ បង្ហាញថា គណបក្សកាន់អំណាចបាននិង កំពុងព្យាយាមធ្វើឲ្យគណបក្សប្រឆាំងចុះខ្សោយ និងបំបិទសម្លេងគណៈបក្សប្រឆាំង ក្នុងគោលបំណង បន្តុចបង្អាក់ដល់ការបោះឆ្នោតឃុំ- សង្កាត់ ឆ្នាំ២០១៧ និងការបោះឆ្នោតជាតិ ឆ្នាំ២០១៨ នាពេលខាង មុខនេះ ដោយផាត់ចេញថ្នាក់ដឹកនាំ និងសមាជិកសំខាន់ៗរបស់គណៈបក្សប្រឆាំងដ៏ធំមួយនៅកម្ពុជា មិនឲ្យឈរឈ្មោះបោះឆ្នោត និងការធ្វើយុទ្ធនាការបោះឆ្នោតដោយសេរី ដោយរួមមានទាំងការដាក់ពួក គេក្នុងពន្ធនាគារ ការធ្វើនិរទេសខ្លួន ឬការព្យួរការចោទប្រកាន់ និងការគំរាមកំហែងជាអចិន្ត្រៃយ៍ចាប់ខ្លួន ពួកគេ; និងថា គណៈបក្សសង្គ្រោះជាតិនៅតែបន្តធ្វើពហិការការងារសភា និងបានដាក់ញត្តិទៅព្រះ មហាក្សត្រ ដើម្បីជួយសម្រួលដោះស្រាយវិបត្តិនយោបាយដែលកំពុងកើតមាន។

*ដោយយល់ឃើញ*ថា ក្នុងប៉ុន្មានខែកន្លងមកនេះ មានការកើនឡើងនូវចំនួនរដ្ឋ និងអង្គការអន្តរ ជាតិនានា រួមទាំងអង្គការសហប្រជាជាតិផង បានសម្តែងកង្វល់យ៉ាងខ្លាំងអំពីការធ្លាក់ចុះនូវស្ថានភាព សិទ្ធិមនុស្ស និងនយោបាយនៅកម្ពុជា ជាពិសេសបរិយាកាសកាន់តែអាក្រក់សម្រាប់អ្នកនយោបាយ គណៈបក្សប្រឆាំង និងសកម្មជនសិទ្ធិមនុស្សនៅកម្ពុជា ដោយសារតែមានការរីករាលដាលខ្លាំងឡើងនូវ ការចោទប្រកាន់ ដោយហេតុផលនយោបាយ ការយាយីតាមផ្លូវតុលាការ និងអំពើហឹង្សា។ ពួកគេបាន ជម្រុញឲ្យរដ្ឋាភិបាលកម្ពុជា ធានាឲ្យបានពេញលេញនូវការគោរពសិទ្ធិមនុស្ស រួមទាំងសេរីភាពក្នុងការ បញ្ចេញមតិ និងក្នុងការជួបប្រជុំ និងការប្រកាន់ខ្ជាប់យ៉ាងមុតមាំចំពោះបទដ្ឋានអន្តរជាតិស្តីពីការជំនុំ ជម្រះប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ដើម្បីធានាថា ច្បាប់ត្រូវបានអនុវត្តដោយគ្មានការរើសអើង ដោយឈរលើហេតុផលណាមួយឡើយ។ ពួកគេបានអំពាវនាវឲ្យមានការបន្តជាបន្ទាន់នូវកិច្ចសន្ទនា នយោបាយរវាងគណៈបក្សប្រជាជនកម្ពុជា និងគណៈបក្សសង្គ្រោះជាតិ និងដើម្បីបង្កើតបរិយាកាស នយោបាយមួយដែលក្នុងនោះគណៈបក្សប្រឆាំង និងសង្គមស៊ីវិល អាចធ្វើការបានដោយសេរីទាំងអស់ គ្នា ដោយមិនភ័យខ្លាចមានការចាប់ខ្លួន ឬការធ្វើទុក្ខបុកម្នេញ ដើម្បីឲ្យកម្ពុជាអាចធ្វើការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ ដែលអាចធានានីត្យានុកូលភាពរបស់រដ្ឋាភិបាលបន្ទាប់។ ក្នុងសេចក្តីសម្រេច ចិត្ត ដែលបានអនុម័តនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ សភាអឺរ៉ុបបានរំលឹកថា បរិយាកាសមួយដែល គ្មានការគំរាមកំហែងនៃកិច្ចសន្ទនាបែបប្រជាធិបតេយ្យ គឺសំខាន់សម្រាប់ស្ថិរភាពនយោបាយ លទ្ធិ ប្រជាធិបតេយ្យ និងសង្គមមួយមានសុខសន្តិភាព និងបានជម្រុញឲ្យរដ្ឋាភិបាលចាត់វិធានការចាំបាច់ គ្រប់បែបយ៉ាង ដើម្បីធានាសន្តិសុខរបស់តំណាងរាស្ត្រគ្រប់រូបដែលជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ នៅកម្ពុជា ដោយមិនគិតពីនិន្នាការនយោបាយរបស់ពួកគេឡើយ។ សេចក្តីសម្រេចចិត្តនេះ បានជម្រុញ ឲ្យអាជ្ញាធរកម្ពុជាលុបចោលដីកាចាប់ខ្លួន និងទម្លាក់ចោលរាល់ការចោទប្រកាន់លើមេដឹកនាំគណៈបក្ស ប្រឆាំង និងតំណាងរាស្ត្រគណៈបក្សសង្គ្រោះជាតិ ព្រមទាំងធ្វើឲ្យពួកគេមានឋានៈដូចដើមវិញភ្លាមៗ និងស្តារអភ័យឯកសិទ្ធិសភារបស់ពួកគេឡើងវិញ។

*ដោយយល់ឃើញថា* ជំនួបកិច្ចប្រជុំចំនួនពីរ បានធ្វើដាច់ដោយឡែកពីគ្នា ដែលជំនួបកិច្ចប្រជុំ

មួយបានធ្វើឡើងជាមួយគណៈប្រតិភូកម្ពុជាដែលចូលរួមក្នុងសម័យប្រជុំលើកទី១៣៥ របស់សហភាពអន្តរសភាIPU ហើយជំនួបកិច្ចប្រជុំមួយទៀត បានធ្វើឡើងជាមួយមេដឹកនាំគណៈបក្សប្រឆាំងរបស់កម្ពុជា លោក សម រង្ស៊ី; *យល់ឃើញថា* ពួកគេបានបញ្ជាក់ឡើងវិញពីជំហររបស់ពួកគេកន្លងមក លើករណីរឿងក្តីទាំងនេះ *និងថា* ពួកគេបានបញ្ជាក់ពីឆន្ទៈរបស់ខ្លួនរៀងៗខ្លួនក្នុងការធ្វើការដើម្បីឧត្តមផលប្រយោជន៍របស់ប្រជាជនកម្ពុជា និងដើម្បីបន្តកិច្ចសន្ទនានយោបាយ ដែលភាគីទាំងពីរបានអំពាវនាវឲ្យសភាIPU ជួយធ្វើឲ្យដើម្បីសម្រេចគោលដៅនេះ; និងដែលលើសពីនេះទៀតៈ

- លោក សម រង្ស៊ី បានបញ្ជាក់ថា គាត់ត្រូវបានលោកនាយករដ្ឋមន្ត្រីហាមឃាត់ការវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ និងការចូលរួមក្នុងដំណើរការបោះឆ្នោតនាពេលខាងមុខ និងបានសម្តែងកង្វល់អំពីភាពត្រឹមត្រូវនៃដំណើរការបោះឆ្នោតនាពេលខាងមុខ ប្រសិនបើគណៈបក្សសង្គ្រោះជាតិ មិនអាចចូលរួមពេញលេញ និងដោយសេរីទេនោះ។

- គណៈប្រតិភូបានគូសបញ្ជាក់ថា គេបានសង្ឃឹមថាការរីកចម្រើនអាចនឹងសម្រេចបានលើករណីរឿងក្តីទាំងនេះ នៅសម័យប្រជុំបន្ទាប់របស់សភាIPU។ គណៈប្រតិភូបានសង្កេតឃើញថា គណៈបក្សសង្គ្រោះជាតិបានស្ថិតក្នុងចំណោមគណៈបក្សនយោបាយចំនួន ៥៨ ដែលបានចុះឈ្មោះសម្រាប់ការបោះឆ្នោតនាពេលខាងមុខនេះ និងអាចចូលរួមក្នុងការដំណើរការបោះឆ្នោត ហើយមានតែសមាជិកដែលបានប្រព្រឹត្តបទល្មើសប៉ុណ្ណោះ ដែលត្រូវបានរារាំងការចូលរួម ហើយគណៈបក្សនេះមានសេរីភាពក្នុងការតែងតាំងមេដឹកនាំថ្មី ដែលអាចឈរឈ្មោះបោះឆ្នោតបាន។ សេចក្តីសម្រេចរបស់តុលាការ មិនបានរារាំងលោក កឹម សុខា ឲ្យចាកចេញពីទីស្នាក់ការកណ្តាលរបស់គណៈបក្សសង្គ្រោះជាតិទេ ហើយគាត់ក៏បានទៅចុះឈ្មោះបោះឆ្នោតរួចហើយដែរ។ សេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជាគឺ ខុសគ្នាពីបណ្តាប្រទេសលោកខាងលិចផ្សេងទៀត ដែលត្រូវតែមានតុល្យភាពជាមួយនឹងតម្រូវការស្ថិរភាពក្នុងប្រទេស។ មានតែ "ការរិះគន់យ៉ាងពិតប្រាកដ" របស់លោកនាយករដ្ឋមន្ត្រីទេ ដែលត្រូវបានអនុញ្ញាត។ គណៈបក្សប្រឆាំងនឹងមិនស្ថិតក្នុងស្ថានភាពបច្ចុប្បន្ននេះទេ ប្រសិនជាគេបានបញ្ឈប់ "ចាក់សាំងលើភ្លើង" ហើយបានប្រកាន់យកជំហរស្ថាបនាច្រើនជាងនេះ មិនធ្វើជ្រុលដោយការរិះគន់មិនសំចៃដៃទៅលើលោកនាយករដ្ឋមន្ត្រី និងទៅលើរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

*ដោយចងចាំក្នុងចិត្ត* នូវចំណុចខាងក្រោមនេះ ចំពោះកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ក្នុងការគោរព ការការពារ និងការលើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋានៈ

- ក្នុងនាមជារដ្ឋភាគីមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កម្ពុជាមានកាតព្វកិច្ចគោរពបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងសិទ្ធិជាមូលដ្ឋានខាងសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការជួបប្រជុំ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងការជំនុំជម្រះក្តី

ប្រកបដោយយុត្តិធម៌ ដែលធ្វើឡើងដោយតុលាការមួយឯករាជ្យនិងមិនលំអៀង និងដើម្បីចូលរួមក្នុងកិច្ចការសាធារណៈ។ ការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការបង្កើតសមាគម អនុញ្ញាតបានតែក្នុងករណីចាំបាច់បំផុត ដើម្បីការពារសិទ្ធិរបស់អ្នកដទៃ ឬក្នុងករណីមានការគំរាមកំហែងធ្ងន់ធ្ងរដល់សន្តិសុខសាធារណៈ ហើយការរឹតត្បិតនោះទៀតសោត គួរតែមានសមាមាត្រទៅនឹងគោលបំណងដែលចង់បាន វិសាលភាព និងរយៈពេលត្រូវមានកំណត់ ហើយត្រូវមានការត្រួតពិនិត្យពីតុលាការឯករាជ្យ ស្របតាមមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសេចក្តីសម្រេចចិត្តរបស់សភាIPU ស្តីពីសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន ដែលបានអនុម័តនាសម័យប្រជុំលើកទី១២០ របស់សភាIPU (អាដឌីស អាបាបា ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩)។

- បន្ទាប់ពីវដ្តទី២ នៃការពិនិត្យជាសកលតាមកាលកំណត់(UPR)របស់កម្ពុជា ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅឆ្នាំ២០១៤ អាជ្ញាធរកម្ពុជា បានទទួលយកអនុសាសន៍ដើម្បី "លើកកម្ពស់បរិយាកាសអំណោយផល និងមានសុវត្ថិភាព ដែលអនុញ្ញាតឲ្យបុគ្គលនានា និងក្រុមទាំងឡាយ អាចអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងបញ្ឈប់ការយាយី ការគំរាមកំហែង ការចាប់ខ្លួនតាមអំពើចិត្ត និងការវាយប្រហារលើរូបកាយ ជាពិសេសនៅក្នុងបរិបទនៃការធ្វើបាតុកម្មដោយសន្តិវិធី" និង "ចាត់វាល់វិធានការចាំបាច់ ដើម្បីធានាការពារឯករាជ្យភាពរបស់តុលាការ ដោយមិនមានការគ្រប់គ្រង ឬការជ្រៀតជ្រែកខាងនយោបាយ" (របាយការណ៍របស់ក្រុមការងារ UPR នៃប្រទេសកម្ពុជា A/HRC/26/16)។

*ដោយចងចាំក្នុងចិត្តផងដែរ* ជំពូក ៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេស មាត្រា ៣១ ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស (....)" ព្រមទាំងមាត្រា៨០ និង មាត្រា១០៤ នៃរដ្ឋធម្មនុញ្ញ ចែងថា៖ (១) តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា (២) តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ (៣) ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា (៤) ក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនរដ្ឋសភា ហើយស្នើសុំការយល់ព្រមពីរដ្ឋសភា (៥) ការដកអភ័យឯកសិទ្ធិសភា ត្រូវមានការយល់ព្រមដោយអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកសភាទាំងមូល ហើយ (៦) សភាអាចស្នើឲ្យផ្អាកការឃុំខ្លួន ឬការចោទប្រកាន់សមាជិកសភាណាមួយ ដោយអនុម័តតាមមតិភាគច្រើនបីភាគបួននៃសមាជិកសភាទាំងមូល។

១. *សូមថ្លែងអំណរគុណ* ចំពោះគណៈកម្មាធិការសម្រាប់របាយការណ៍ចុងក្រោយនៃដំណើរទស្សនកិច្ចរបស់ខ្លួនមកកាន់ប្រទេសកម្ពុជា និងអនុម័តគាំទ្រសេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់ខ្លួន។ *ដោយកត់សម្គាល់*លើសេចក្តីសង្កេតដែលផ្តល់ដោយអាជ្ញាធរកម្ពុជា និង*សូមអរគុណបន្ថែមទៀត* ដល់ភាគីទាំងពីរសម្រាប់ការចែករំលែកទស្សនៈរបស់ខ្លួនរៀងៗខ្លួន ជាមួយគណៈកម្មាធិការ។

*២. កត់សម្គាល់ដោយប្លែកចិត្ត*ថា មិនការរីកចម្រើនណាមួយ បានធ្វើឡើងក្នុងការដោះស្រាយករណីរឿងក្តីទាំងនេះ ហើយថាស្ថានភាពនេះ បានរីករាលដាលខ្លាំងឡើងថែមទៀត

៣. *មានកង្វល់យ៉ាងខ្លាំង* ថាសមាជិកសភាចំនួនសរុប ១៥ រូប នៃគណៈបក្សប្រឆាំង រួមទាំងមេដឹកនាំនៃគណៈបក្សប្រឆាំងដ៏ធំនេះផង បន្តប្រឈមការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ហើយកំពុងត្រូវបានរារាំងដល់ការបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងនាមជាសមាជិកសភា និងជាសមាជិកគណបក្សប្រឆាំង ដោយសេរី ដោយគ្មានការភ័យខ្លាចការធ្វើទុក្ខបុកម្នេញ ជាពិសេសដោយសារការបោះឆ្នោតឃុំ-សង្កាត់ និងការបោះឆ្នោតជាតិ ដែលខិតជិតយ៉ាងលឿននេះ។

*៤. សូមជម្រុញជាថ្មីម្តងទៀត* ដល់អាជ្ញាធរកម្ពុជាឲ្យធានាឲ្យបានពេញលេញនូវការគោរពសិទ្ធិមនុស្ស ហើយថាច្បាប់ត្រូវតែបានអនុវត្តដោយគ្មានការរើសអើង។ *សូមអំពាវនាវជាថ្មី* ដល់អង្គនៃអំណាចទាំងអស់ និងគ្រប់គណៈបក្សនយោបាយឲ្យចាប់ដៃគ្នាធ្វើការដើម្បីធានាថា៖

១) មានការគោរពពេញលេញចំពោះអភ័យឯកសិទ្ធិសភា និងចំពោះអាណត្តិសភាដែលប្រជាពលរដ្ឋកម្ពុជាបានប្រគល់ឲ្យសមាជិកសភា ព្រមទាំងសិទ្ធិសេរីភាពរបស់សភាទាំងនោះក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី សិទ្ធិទទួលបានតុលាការឯករាជ្យ និងដំណើរការនីតិវិធីរបស់តុលាការប្រកបដោយយុត្តិធម៌ រាប់ទាំងច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា អនុលោមតាមបទដ្ឋានអន្តរជាតិ និងទម្លាប់អនុវត្តន៍របស់សភាប្រជាធិបតេយ្យ។

(២) ជនដែលបានញុះញង់ និងធ្វើការវាយប្រហារ គំរាមកំហែង និងបំភិតបំភ័យតំណាងរាស្ត្រត្រូវតែដាក់ឲ្យទទួលខុសត្រូវ ហើយថា នៅថ្ងៃអនាគត អាជ្ញាធរពាក់ព័ន្ធត្រូវផ្តល់វិធានការការពារជាប្រព័ន្ធឲ្យបានឆាប់ និងមានប្រសិទ្ធភាព នៅពេលដែលសមាជិកសភាយល់ថាខ្លួនកំពុងទទួលរងការគំរាមកំហែង។

៣) ការបន្តដំណើរការនីតិវិធីតុលាការទៅលើសាមីសមាជិកសភា ត្រូវតែបញ្ចប់ដោយមិនមានការពន្យាពេល ក្នុងលក្ខណៈមួយត្រឹមត្រូវ យុត្តិធម៌ ឯករាជ្យ មិនលំអៀង និងមានតម្លាភាព រាប់ទាំង - នៅពេលដែលមានការបង្ហាញភស្តុតាងដោះបន្ទុក និងស្ថាន

សម្រាលទោស - តាមរយៈសេចក្តីសម្រេចទម្លាក់ចោលការចោទប្រកាន់ ឬ ដូរបទចោទប្រកាន់ បញ្ឈប់កិច្ចដំណើរការនីតិវិធី ឬដោះលែងជនសង្ស័យ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងរដ្ឋធម្មនុញ្ញកម្ពុជា ដែលតម្រូវឲ្យគោរពគោលការណ៍សច្ចធារណ៍នៃនិរទោស និងសិទ្ធិរបស់ជនជាប់ចោទ។

៥. *បន្តយល់ឃើញ* ថាវាជាការសំខាន់ណាស់ដែលគណៈបក្សកាន់អំណាច និងគណៈបក្សប្រឆាំងបន្តកិច្ចសន្ទនានយោបាយ សំដៅបង្កើតបរិយាកាសនយោបាយមួយមានស្ថិរភាព ដែលក្នុងនោះមានលំហគ្រប់គ្រាន់សម្រាប់មតិមិនស្រប និងសម្រាប់ការអនុវត្តដោយសន្តិវិធីនូវសេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ក្នុងបរិបទនៃការបោះឆ្នោតដែលខិតជិតយ៉ាងលឿននេះ។ *ដោយជឿជាក់ថា* ការធ្វើឲ្យមានវឌ្ឍនភាពឈានទៅរកការដោះស្រាយប្រកបដោយចិរភាពនូវបណ្តឹងលក្ខណៈជាបុគ្គលដោយគោរពតាមបទដ្ឋានសិទ្ធិមនុស្សអាចត្រួសត្រាយផ្លូវសម្រាប់ការបន្តកិច្ចសន្ទនានយោបាយប្រកបដោយន័យស្ថាបនា និងរួមចំណែកដល់ការបង្កើតឲ្យមានបរិយាកាសនយោបាយមួយអំណោយផលដល់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ *ដោយបញ្ជាក់ជាថ្មី* អំពីការត្រៀមខ្លួនជាស្រេចរបស់សភា IPU ក្នុងការជួយសម្រួលដល់កិច្ចសន្ទនានយោបាយ និងផ្តល់ជំនួយបច្ចេកទេសដល់សភាកម្ពុជា។

៦. *ស្នើសុំឲ្យ*អគ្គលេខាធិការពាំនាំនូវសេចក្តីសម្រេចនេះឲ្យបានដឹងដល់អាជ្ញាធរមានសមត្ថកិច្ច អ្នកប្តឹង និងភាគីទីបីណាមួយ ដែលអាចមានតួនាទីក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនានា។

៧. *ស្នើសុំឲ្យ*គណៈកម្មាធិការបន្តពិនិត្យមើលករណីសំណុំរឿងទាំងនេះ និងរាយការណ៍ត្រឡប់មកវិញ តាមពេលវេលាសមស្រប។

**ចប់**